Asian American Health Initiative

# សន្លឹកព័ត៌មានរោគមហារីកក្រពេញប្រូស្តាត

## តើរោគមហារីកក្រពេញប្រូស្តាតគឺជាអ្វី ?

ក្រពេញប្រូស្តាត គឺជាក្រពេញដែលបង្កើតសារធាតុរាវទឹកកាម និងមានទំហំប្រមាណប៉ុនដើមវ៉ាលណាត់ ឬគ្រាប់ប៉េងប៉ុះ ។ វាស្ថិតនៅក្រោមប្លោកនោម និងនៅពីមុខពោះវៀន ។ រោគមហារីកកើតឡើងនៅពេលដែលកោសិកាក្នុងក្រពេញប្រូស្តាតប្រែប្រួល ហើយរីកសាយមិនអាចគ្រប់គ្រងបាន ។




ក្រពេញប្រូស្តាតធម្មតា ក្រពេញប្រូស្តាតរីកធំ

## កត្តាប្រថុយគ្រោះថ្នាក់

មូលហេតុបណ្តាលឱ្យមានរោគមហារីកក្រពេញប្រូស្តាតមិនត្រូវបានដឹងនៅឡើយទេ តែអ្នកស្រាវជ្រាវបានរកឃើញកត្តាជាច្រើនដែលបង្កើន ការប្រថុយគ្រោះថ្នាក់ឱ្យមានរោគមហារីកនេះ :

- **អាយុ 50 និងលើសពីនេះ**
- **ពូជអម្បូរ**
- **ប្រវត្តិគ្រួសារ**
- **ការតមអាហារធាត់ខ្លាំងពេក**
- **ការពិសាបារី**

## រោគសញ្ញា

រោគមហារីកក្រពេញប្រូស្តាត ជាធម្មតាមិនបណ្តាលឱ្យមានរោគសញ្ញានៅក្នុងដំណាក់កាលដំបូងរបស់វានោះទេ ។ មនុស្សប្រុសជាច្រើនមិនដឹងថា ពួកគេមានរោគនេះទេ លុះត្រាតែវាត្រូវបានរកឃើញក្នុងកំឡុងពេលពិនិត្យសុខភាពជាទៀងទាត់ ។ ប្រសិនបើមានរោគសញ្ញា ពួកវាអាចមានដូចជា :

- **ពិបាកនោម**
- **នោមញឹកញាប់**
- **ឈឺចាប់ ឬមានអារម្មណ៍ក្តៅនៅពេលអ្នកនោម**
- **ឈាមនៅក្នុងទឹកនោម**

## ការបង្ការ/ការរកឃើញទាន់ពេល

ចួនកាល រោគមហារីកក្រពេញប្រូស្តាតត្រូវបានស្គាល់ថាជាឃាដកដ៏ស្ងប់ស្ងាត់ ដោយសារវាតែងតែមិនមានរោគសញ្ញា ។ នេះគឺជាមូលហេតុដែលធ្វើឱ្យត្រូវបានណែនាំឱ្យធ្វើតេស្តពិនិត្យជារៀងរាល់ឆ្នាំ នៅពេលបុរសឈានដល់អាយុ 50 ឬមុននេះប្រសិនបើគាត់ស្ថិតក្នុងការប្រថុយគ្រោះថ្នាក់ខ្ពស់ ។

## ការណែនាំពិនិត្យរោគមហារីកក្រពេញប្រូស្តាត

ចាប់ពីអាយុ 50 បុរសគួរតែមានការធ្វើតេស្តពិនិត្យប្រចាំឆ្នាំលើចំណុចទាំងពីរនេះ :

- **ពិនិត្យមើលពោះវៀនត្រង់ឌីជីថល (DRE)**
- ធ្វើតេស្តឈាម**អង់ទីហ្សែនក្រពេញប្រូស្តាតជាក់លាក់ (PSA)** ដែលអាចរកឃើញការមានរោគមហារីក ។

ប្រសិនបើការធ្វើតេស្តទាំងនេះ ឃើញថាមានរោគមហារីកក្រពេញប្រូស្តាត នោះគ្រូពេទ្យអាចណែនាំឱ្យមាន**ជីវជាលិកាសាស្ត្រក្រពេញប្រូស្តាត** ដែលក្នុងនោះជាលិកា ត្រូវបានយកចេញពីក្រពេញប្រូស្តាត និងពិនិត្យមើលតាមអតិសុខុមទស្សន៍ ។

## ការពិនិត្យរោគវិនិច្ឆ័យ និងការព្យាបាល

ការព្យាបាលផ្អែកតាមថាតើរោគមហារីកនេះរីកធំឆាប់រហ័សកម្រិតណា វារីករាលដាលលឿនខ្លាំងប៉ុណ្ណា តាមអាយុ និងអាយុកាលជាមធ្យម ។ ការព្យាបាលអាចរួមមានមួយ ឬច្រើនដូចខាងក្រោមនេះ :

- **រង់ចាំពិនិត្យមើល** មិនពាក់ព័ន្ធការព្យាបាល តែពិនិត្យអង្កេតមើល និងពិនិត្យព្យាបាលយ៉ាងប្រុងប្រយ័ត្ន ។
- **ការព្យាបាលដោយកាំរស្មី** ប្រើប្រាស់កាំរស្មីអ៊ិច ដើម្បីសម្លាប់កោសិការោគមហារីក ។
- **ការព្យាបាលតាមបែបគីមីសាស្ត្រ** ប្រើថ្នាំដើម្បីបញ្ឈប់ការរីកធំរបស់កោសិការោគមហារីកទៅផ្នែកផ្សេងទៀតនៃរាងកាយ ។
- **ការព្យាបាលតាមអរម៉ូន** ពាក់ព័ន្ធនឹងការលេបថ្នាំ ដើម្បីបញ្ឈប់ការរីកធំនៃអរម៉ូន ។
- **ការវះកាត់** គឺជាការយកក្រពេញប្រូស្តាតចេញ ។

## សន្និដ្ឋាន

រោគមហារីកក្រពេញប្រូស្តាត គឺជាមូលហេតុចម្បងបំផុតនៃការស្លាប់របស់បុរសដែលមានអាយុច្រើនជាង 40 ។ អត្រារោគមហារីកក្រពេញប្រូស្តាតចំពោះបុរសអាមេរិកកាត់អាស៊ី កើនឡើងនៅពេលដែលពួកគេធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក ដែលប្រហែលជាដោយសារតែការផ្លាស់ប្តូរបរិយាកាស (ឧទាហរណ៍ ការតមអាហារធាត់ខ្លាំងពេក ការពិសាបារី) ។ ប្រសិនបើរោគមហារីកក្រពេញប្រូស្តាតត្រូវបានរកឃើញទាន់ពេល ឱកាសព្យាបាលជោគជ័យដោយមានផលប៉ះពាល់តិចបំផុត ឬរយៈពេលខ្លី នឹងត្រូវបានកើនឡើងយ៉ាងខ្លាំង ។ វាជាការសំខាន់ដែលបុរសម្នាក់ៗត្រូវពិភាក្សាជាមួយគ្រូពេទ្យរបស់គាត់ ថាតើពេលណាប្រសើរបំផុតដើម្បីធ្វើការពិនិត្យរោគមហារីកក្រពេញប្រូស្តាត ។

### ចូរចងចាំថា ការរកឃើញទាន់ពេលជួយសង្គ្រោះជីវិតបាន !

សម្រាប់ព័ត៌មានបន្ថែមពីកម្មវិធីពិនិត្យរោគមហារីករបស់យើង សូម**ទូរស័ព្ទទៅលេខ 240-777-1409** ឬចូលទៅកាន់គេហទំព័ររបស់យើងតាម **www.AAHIinfo.org** ។


ប្រភព

***American Cancer Society, Mayo Clinic, MedlinePlus, Patient Health International, WebMed, Wikepidia.***